**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ១៣៣៩ អយក.ប្រក

# ប្រកាស
## ស្ដីពី
## ការបើកបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាកលវិទ្យាល័យបាត់ដំបង

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែល ប្រកាសឱ្យប្រើច្បាប់ ស្ដីពី ការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្ដីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្ដីពី លក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្ដីពី ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២១ ខែ មីនា ឆ្នាំ២០០៧ ស្ដីពី ការបង្កើតសាកលវិទ្យាល័យបាត់ដំបង

- បានឃើញប្រកាសលេខ ១០៤៩ អយក.ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៣ ស្តីពីការបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិត
- បានឃើញប្រកាសលេខ ៧០៦ អយក.ប្រក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការបំពេញបន្ថែមលើប្រកាសលេខ ១០៤៩ អយក.ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៣ ស្តីពី ការបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិត
- បានឃើញប្រកាសលេខ ១៨៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពី លក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
- យោងតាមសំណើរបស់ សាកលវិទ្យាល័យបាត់ដំបង

**សម្រេច**

**ប្រការ១-**

អនុញ្ញាតឱ្យសាកលវិទ្យាល័យបាត់ដំបង បើកបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញនិរន្តរភាព នៃការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី ត្រូវសិក្សារយៈពេលយ៉ាងតិច ២(ពីរ)ឆ្នាំ សមមូលនឹង៤៥(សែសិបប្រាំ)ក្រេឌីតយ៉ាងតិច។

**ប្រការ២-**

សាកលវិទ្យាល័យបាត់ដំបង មានភារកិច្ចៈ

- រៀបចំបទបញ្ញត្តិស្តីពីការគ្រប់គ្រងការសិក្សាសម្រាប់មុខជំនាញខាងលើ
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- អនុវត្តតាមបទដ្ឋានគតិយុត្តិរបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍ស្តីពីការបណ្តុះបណ្តាលមកនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្ររៀងរាល់ឆមាសឱ្យបានទៀងទាត់។

**ប្រការ៣.**

និស្សិតដែលរៀនចប់កម្មវិធីសិក្សាហើយបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ ឬការការពារនិក្ខេបបទបញ្ចប់ការសិក្សាត្រូវទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់តាមមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយសាកលវិទ្យាល័យបាត់ដំបងផ្អែកតាមបញ្ជីឈ្មោះនិស្សិតបានបញ្ចប់ការសិក្សាជាប់ជាស្ថាពរដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤.**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នាយកដ្ឋានឧត្តមសិក្សា សាកលវិទ្យាល័យបាត់ដំបង និងគ្រប់អង្គភាព ដែលពាក់ព័ន្ធត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤ រោច ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៨

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ ន.សវ

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន